**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**មន្ទីរអប់រំ យុវជន និងកីឡា ខេត្តក្រចេះ**
**ក្រុមលទ្ធកម្ម**
លេខ: .០០៤/១៩..អយក១.ក្រច.កល

# សេចក្តីជូនដំណឹងស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃ
## ការងារជួសជុលពង្រីកអាគាររដ្ឋបាល និងសាលប្រជុំ គម្រោងបីជាន់ ដំណាក់កាលទី៤ របស់មន្ទីរអប់រំ យុវជន និងកីឡា ខេត្តក្រចេះ សម្រាប់ឆ្នាំ២០១៩

មន្ទីរអប់រំ យុវជន និងកីឡាខេត្ត សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថាមន្ទីរអប់រំ យុវជន និងកីឡាខេត្ត នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើស "អ្នកទទួលការ" ធ្វើការងារជួសជុលពង្រីកអាគាររដ្ឋបាល និងសាលប្រជុំ គម្រោងបីជាន់ ដំណាក់កាលទី៤ របស់មន្ទីរអប់រំ យុវជន និងកីឡា ខេត្តក្រចេះ សម្រាប់ឆ្នាំ២០១៩។

មន្ទីរអប់រំ យុវជន និងកីឡា បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ។

ឯកសារដេញថ្លៃមានដាក់លក់នៅមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ដែលមានអាសយដ្ឋាន ភូមិក្រចេះ សង្កាត់ក្រចេះ ក្រុងក្រចេះ ខេត្តក្រចេះ ចាប់ពីថ្ងៃទី១៥..ខែ.កក្កដា.. ឆ្នាំ២០១៩ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ ០៧២ ៩៧១ ៤៤៨)។

ឯកសារដេញថ្លៃដែលបានបំពេញរួចត្រូវប្រគល់ជូនក្រុមលទ្ធកម្មមន្ទីរអប់រំ យុវជន និងកីឡា ខេត្តក្រចេះ យ៉ាងយូរបំផុតត្រឹមថ្ងៃទី២៨.. ខែ.សីហា. ឆ្នាំ២០១៩ វេលាម៉ោង...០៨:០០...............។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅក្រុមលទ្ធកម្ម នៃមន្ទីរអប់រំ យុវជន និងកីឡា ខេត្តក្រចេះ តាមអាសយដ្ឋានខាងលើ វេលាម៉ោង...០៨:០០........ ថ្ងៃទី.២៨.. ខែ.សីហា... ឆ្នាំ២០១៩ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃសូមអញ្ជើញទាក់ទងជាមួយក្រុមលទ្ធកម្មរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃ..ពុធ..៨..កើត.... ខែ..អាសាឍ.. ឆ្នាំ..កុរ..ឯកស័ក. ព.ស២៥៦៣
ធ្វើនៅក្រចេះ, ថ្ងៃទី..១០...ខែ.កក្កដា..ឆ្នាំ២០១៩
**ប្រធានមន្ទីរ និង ជាប្រធានក្រុមលទ្ធកម្ម**

**ឡាយ បូរ៉ា**

**ចម្លងជូន÷**
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពលទ្ធកម្ម នៃក្រសួងអប់រំ យុវជន និងកីឡា
-អង្គភាពប្រឆាំងអំពើពុករលួយ
-ឯកសារ "កាលប្បវត្តិ"



បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ